ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

***

ឆ្នាំទី ៤ លេខ ២៨ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

ក

មាតិកា

I ទីស្តីការគណៈរដ្ឋមន្ត្រី

១—អនុក្រឹត្យ

២៦.៧.៩៦	អនុក្រឹត្យលេខ ៣៦ អនក្របក ស្តីពីអត្តសញ្ញាណប័ណ្ណ សញ្ជាតិខ្មែរ	១២២៦
២៥.៧.៩៦	អនុក្រឹត្យលេខ ១៣២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	១២៣០
២៥.៧.៩៦	អនុក្រឹត្យលេខ ១៣៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	១២៣១
២៩.៧.៩៦	អនុក្រឹត្យលេខ ១៣៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	១២៣២
២៩.៧.៩៦	អនុក្រឹត្យលេខ ១៣៥ អនក្រ.តត ស្តីពីការតែងតាំង និង ផ្ទេរភារកិច្ច មុខតំណែងនាយនគរបាលជាតិ	១២៣៣
៣០.៧.៩៦	អនុក្រឹត្យលេខ ១៣៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	១២៣៧
៣០.៧.៩៦	អនុក្រឹត្យលេខ ១៣៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	១២៣៨
៣០.៧.៩៦	អនុក្រឹត្យលេខ ១៣៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	១២៣៩
៣០.៧.៩៦	អនុក្រឹត្យលេខ ១៣៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	១២៤០
៣១.៧.៩៦	អនុក្រឹត្យលេខ ១៤០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	១២៤១

២—សេចក្តីសំរេច

២៩.៧.៩៦	សេចក្តីសំរេចលេខ ៣០ សសរ ស្តីពីការប្តូរឈ្មោះមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកណ្តាល ទៅជាមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ហ៊ុន សែន ខេត្តកណ្តាល	១២៤២

៣— សារាចរណែនាំ

៣០.៧.៩៦	សារាចរណែនាំលេខ ០៤ ស.រ.ណន ស្តីពីការកំណត់គោលការណ៍ការងារធារាសាស្ត្រ	១២៤៣

II ការងារបណ្តាក្រសួង

១—ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

២៤.៧.៩៦	ប្រកាសលេខ ១១៩ សហវ.ប្រក.ប ស្តីពីការទទួលស្គាល់បុគ្គលិក អតីតហរបនាសម្ព័ន្ធរបស់ភាគី រ.ជ.រប.ខ ចំនួន ១០៨ នាក់ និងអ្នកបច្ចេកទេសដែលទើបបញ្ចប់ការសិក្សាពីក្នុង និង ក្រៅប្រទេស ចំនួន ៨៥ នាក់ អោយមកបំរើការងារក្នុងក្របខ័ណ្ឌក្រសួង	១២៤៨
២៤.៧.៩៦	ប្រកាសលេខ ២៦៤ ប្រក.សហវ.ខ ស្តីពីការតែងតាំងមន្ត្រីរាជការ ជាមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ	១២៥៧
២៥.៧.៩៦	ប្រកាសលេខ ២៦៩ សហវ.ប្រក.ខ ស្តីពីការតែងតាំងមន្ត្រីរាជការ	១២៦៣

២—ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាស

២៥.៧.៩៦	ប្រកាសលេខ ៤៨១ ផក.ប្រក ហអនុញ្ញាតអោយក្រុមហ៊ុនស្រាបៀរកម្ពុជា (CAMBODIA BREWERY LIMITED (CBL)) តំណាងលោក ALEXANDER FREDERIC KILJAN VAN HEUVEN សញ្ជាតិ ហូ ឡង់ បង្កើតរោងចក្រផលិតស្រាបៀរ	១២៦៤
៣១.៧.៩៦	ប្រកាសលេខ ៤៨២ ផក.ប្រក អនុញ្ញាតអោយលោក ហ៊ត ស៊ាង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១២០ សេះ	១២៦៥
៣១.៧.៩៦	ប្រកាសលេខ ៤៨៣ ផក.ប្រក អនុញ្ញាតអោយលោក ឡាំ គឹមភាវ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតស្ករគ្រាប់	១២៦៦

៣១.៧.៩៦ ប្រកាសលេខ ៤៨៤ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ភូ គីមហឿន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៦៥ សេះ ១២៦៦

៣១.៧.៩៦ ប្រកាសលេខ ៤៨៥ ផក.ប្រក អនុញ្ញាតអោយលោក លី ឆាយ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតទឹកស៊ីអ៊ីវ ទឹកត្រី ទឹកម្ទេស និង ទឹកក្បុង ១២៦៧

៣—ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ

ប្រកាស

២៦.៧.៩៦ ប្រកាសលេខ ៤៤១ ប្រក.កសក.ចត ស្តីពីការបង្កើតស្ថានីយ៍ដាំឈើ ១២៦៨

៤—ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

ប្រកាស

២៦.៧.៩៦ ប្រកាសលេខ ៦៦៤ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សាសម្តេច ហ៊ុន សែន ស៊ីវសន្ទាយ ១២៦៩

៥—ទីស្តីការក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន

ប្រកាស

២៨.៧.៩៦ ប្រកាសលេខ ៦៤០ សកអ ស្តីពីការបង្កើតការិយាល័យអាស៊ាន ១២៧១

៦—ទីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

២—សេចក្តីសំរេច

៣១.៧.៩៦ សេចក្តីសំរេចលេខ ១២៩ បទ ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យតាមក្រុមហ៊ុនដែលធ្វើអាជីវកម្មសេវាប្រៃសណីយ៍ក្នុងរាជធានីភ្នំពេញ ១២៧២

I ទីស្ដីការគណៈរដ្ឋមន្ត្រី

១— អនុក្រឹត្យ

រាជធានីភ្នំពេញ , ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ៣៦ អនក្រ.បក

ស្ដីពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

* * *

រាជរដ្ឋាភិបាល

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង នាយក រដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២

–បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

–បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

–បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤–៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

–បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤–៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

–បានឃើញព្រះរាជក្រមលេខ នស.រកត ១៩៦–០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ

–បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ

–តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

–តាមការយល់ព្រមនៃគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា ១ : ត្រូវបានបង្កើតអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដូចមានគំរូថែងក្នុងឧបសម្ព័ន្ធ នៃអនុក្រឹត្យ នេះ ។

មាត្រា ២ : អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ មានសុពលភាព ១០ ឆ្នាំ ចាប់ពីថ្ងៃចេញអត្តសញ្ញាណប័ណ្ណនេះ ។

មាត្រា ៣ : អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ អាចផ្តល់ជូនបានចំពោះតែ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុចាប់ពី ១៨ ឆ្នាំ ឡើងទៅ ។

មាត្រា ៤ : ក្នុងការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ អាជ្ញាធរមានសមត្ថកិច្ច ត្រូវពិនិត្យ ÷

– សំបុត្រកំណើត ឬ

–សាលក្រមរបស់តុលាការបញ្ជាក់ទទួលស្គាល់ថាជននោះកើតពីឪពុក ឬ ម្តាយ ដែលមានសញ្ជាតិខ្មែរ

–ព្រះរាជក្រឹត្យប្រកាសទទួលស្គាល់ការសុំទាមទារសញ្ជាតិខ្មែររបស់សាមីជន ឬ

–ព្រះរាជក្រឹត្យប្រកាសទទួលស្គាល់ការសុំចូលសញ្ជាតិខ្មែររបស់សាមីជន ឬ

–ឯកសារ ឬ ភស្តុតាងបញ្ជាក់ថាសាមីជន កើតនៅកម្ពុជា ពីឪពុក ឬ ម្តាយ ដែលកើតនៅកម្ពុជា ឬ

–ឯកសារ ឬ ភស្តុតាងបញ្ជាក់ថាសាមីជនធ្លាប់មានសញ្ជាតិខ្មែរ ឬ

–ឯកសារ ឬ ភស្តុតាងបញ្ជាក់ថាសាមីជន កើតពីឪពុក ឬ ម្តាយមានសញ្ជាតិខ្មែរ ឬ

–ឯកសារណាមួយ ដែលអាចបញ្ជាក់បានថា ជននោះជាប្រជាពលរដ្ឋខ្មែរ ។

ក្នុងការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ មន្ត្រីមានសមត្ថកិច្ច ត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនតាមទោសសប្បញ្ញត្តិ នៃច្បាប់ស្តីពីសញ្ជាតិ ក្នុងករណីដែលខ្លួនចេញអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរអោយជនណាម្នាក់ដែលពុំមានសញ្ជាតិខ្មែរ ។

មាត្រា ៥ : បែបបទនៃការសុំអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ក្នុងការទទួលស្គាល់ភស្តុតាងបញ្ជាក់អំពីសញ្ជាតិត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃដោយមានការយល់ព្រមពីរាជរដ្ឋាភិបាល ។

មាត្រា ៦ : មានតែ មន្ត្រីដែលមានមុខតំណែង អភិបាលខេត្ត ក្រុង ជាមន្ត្រីមានសមត្ថកិច្ចក្នុងការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

មន្ត្រីនេះមិនអាចផ្ទេរ ឬ ប្រគល់សិទ្ធិអំណាចនេះអោយមន្ត្រីម្នាក់ទៀតបានឡើយ ។

មាត្រា ៧ : អ្នកសុំអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ត្រូវបង់អាករ តាមការកំណត់របស់ប្រកាសអន្តរក្រសួងមហាផ្ទៃ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា ៨ : ថ្លៃអាករនេះត្រូវបង់ចូលថវិកាជាតិ ។

បែបបទនៃការប្រមូលអាករនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងមហាផ្ទៃ ។

មាត្រា ៩ : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ១០ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីមុខងារសាធារណៈ គ្រប់ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១
ព្រះហស្តលេខានិងត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី២
ហត្ថលេខានិងត្រា
ហ៊ុន សែន

បានបង្គំទូលថ្វាយ និង ជំរាបជូន
សម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១
និង សម្តេចនាយករដ្ឋមន្ត្រីទី ២
សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ស ខេង **យូ ហុកគ្រី**

* * *

ឧបសម្ព័ន្ធនៃអនុក្រឹត្យ ស្តីពីការបង្កើតអត្តសញ្ញាណប័ណ្ណ សញ្ជាតិខ្មែរ





រាជធានីភ្នំពេញ , ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ១៣២ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្ត កំពង់ស្ពឺ

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ « មាស » ស្ថាបនាជាតិ ជូនចំពោះលោក **អៀ ចេងអ៊ាង** និង ភរិយា ប្រធានក្រុមហ៊ុនត្បូងពេជ្រ នៅរដ្ឋឡូសអង់ហ្សឺឡេស សហរដ្ឋអាមេរិក ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ចំនួន ៣០.០៨៧ ដុល្លារ សហរដ្ឋអាមេរិក សំរាប់សាងសង់អាគារសិក្សា ឧបដ្ឋានសាលា និងស្រះទឹក នៅវត្តអង្គប្រាសាទ ឃុំច្បារមន ស្រុកច្បារមន ខេត្តកំពង់ស្ពឺ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ , ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ១៣៣ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា ១ : តែងតាំងលោក **តាន់ បឿន** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាប្រធាននាយកដ្ឋាននេះ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការនៃរដ្ឋលេខាធិដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងស្ថាប័នពាក់ព័ន្ធ និងលោក **តាន់ បឿន** ត្រូវអនុវត្តអនុក្រឹត្យនេះដែលចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ១៣៤ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ « មាស » ស្ថាបនាជាតិ ជូនចំពោះសប្បុរសជន និងអង្គការអន្តរជាតិដែលបានបរិច្ចាគថវិកាជួយកសាង វិស័យអប់រំយុវជន និងកីឡា នៅក្នុងខេត្តកំពង់ធំ ដូចមានរាយនាមខាងក្រោមនេះ ÷

១-អង្គការ CWS តំណាងដោយលោក **ម៉ាន់ ម៉ើរ៉ា** បរិច្ចាគប្រាក់១១០.២៧០$US

២-ឯកឧត្តម **ទៅ ម៉េងលាត** បរិច្ចាគប្រាក់១០០.០០០$US

៣-អង្គការ APS តំណាងដោយលោក CALCAGNO CRISTLANO បរិច្ចាគប្រាក់ ៦៨.៣០១, ៣១$ US

៤-ឯកឧត្តម **ជា ចាន់តូ** និងលោកជំទាវ **ខៀវ ស៊ីណា** បរិច្ចាគប្រាក់ ៩៨.៥៣៧.០០០រៀល

៥-ឯកឧត្តម **ខួន ញឹល** និងលោកជំទាវ **ញៀម សុផានី** បរិច្ចាគប្រាក់ ១២.០០០$ US និង **២៧**.០០០.០០០ រៀល

៦-អង្គការទស្សនៈពិភពលោក តំណាងដោយលោក **សួន ប៊ុន្នា** បរិច្ចាគប្រាក់

៣៥.៦៦៩ $ US

៧-អង្គការ ICS បរិច្ចាគប្រាក់ ២៧.០០០ $ US

៨-អង្គការ ACR តំណាងដោយលោកស្រី ONESTA បរិច្ចាគប្រាក់

១៩.២០០ $ US

៩-ស្ថានទូត នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ តំណាងដោយលោកជំទាវ SUSANNE BANMAU បរិច្ចាគប្រាក់ ១៥.២២៣,៧៦ $ US

១០-លោកឧកញ៉ា **សំអាង** និងលោកជំទាវ **ឈុន លាង** បរិច្ចាគប្រាក់

២៣.០០០ $ US

១១-លោក **ស ហូ** និងលោកស្រី **អៀង ទ៉ាន់** បរិច្ចាគប្រាក់ ២០.០០០ $ US

១២-លោក **លី ប៊ុននាម** និងអ្នកស្រី **មេ ម៉ាលីយ** បរិច្ចាគប្រាក់

៣៣.៦២៥.៣០០រៀល

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា និងអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ព្រះហស្តលេខានិងត្រា ហត្ថលេខានិងត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ១៣៥ អនក្រ.តត

ស្តីពីការតែងតាំង និងផ្ទេរភារកិច្ច

មុខតំណែងនាយនគរបាលជាតិ

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើជាផ្លូវការនូវច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម ០១៩៦.០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើជាផ្លូវការនូវច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានផ្ទេរភារកិច្ច និង តែងតាំងមុខតំណែងនាយនគរបាលជាតិមួយចំនួនដូចខាងក្រោម ÷

១- ផ្ទេរភារកិច្ចលោក ឧត្តមសេនីយ៍ត្រី **អ៊ុន សាម៉ុន** ពីប្រធានសេនាធិការដ្ឋាននៃអគ្គនាយកដ្ឋាននគរបាលជាតិ អោយទៅបំពេញការងារប្រចាំការនៅសហអគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ។

២- ផ្ទេរភារកិច្ចលោក ឧត្តមសេនីយ៍ត្រី **ម៉ៅ ច័ន្ទតារា** ពីអនុប្រធានទី ១ នាយកដ្ឋានកណ្តាលយុត្តិធម៌ អោយមកទទួលជាប្រធានសេនាធិការដ្ឋាននៃអគ្គនាយកដ្ឋាននគរបាលជាតិ ។

៣- តែងតាំងលោក វរសេនីយ៍ឯក **មាំ ឈឿន** បច្ចុប្បន្នអនុប្រធានទី ១ នាយកដ្ឋាននគរបាល សេដ្ឋកិច្ច ជាអនុប្រធានទី១ នាយកដ្ឋានកណ្តាលយុត្តិធម៌ ។

៤- ផ្ទេរភារកិច្ចលោក **ម៉ែន អ៊ុត** ពីប្រធានអធិការដ្ឋានកិច្ចការនគរបាលនៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល អោយមកទទួល

ជាជំនួយការជោរឯឧត្តម ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

៥–ផ្ទេរភារកិច្ចលោក ឧត្តមសេនីយ៍ត្រី ពត ឡូច ពីអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែនមកជាប្រធានអធិការដ្ឋានកិច្ចការនគរបាលនៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និង នគរបាល ។

៦–តែងតាំងលោក ឧត្តមសេនីយ៍ត្រី ម៉ែន រ៉ាន បច្ចុប្បន្នប្រធាននាយកដ្ឋាននគរបាលព្រំដែនគោកជាអនុប្រធាននាយកដ្ឋានកណ្តាល នគរបាលព្រំដែន ។

៧–ផ្ទេរភារកិច្ចលោកឧត្តមសេនីយ៍ត្រី ចាន់ រ៉ាន ពីអនុប្រធានទី ១ នាយក ដ្ឋានកណ្តាលនគរបាលព្រំដែនអោយមកទទួលជាប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក ។

៨–ផ្ទេរ និងតែងតាំងលោក ឧត្តមសេនីយ៍ត្រី ហ៊ុន នន ពីអនុប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ អោយមកទទួលជាអនុប្រធានទី ១ នាយកដ្ឋានកណ្តាលនគរបាលព្រំដែន ។

៩–ផ្ទេរភារកិច្ចលោកឧត្តមសេនីយ៍ត្រី យិន ស្រ៊ាង ពីប្រធានអង្គភាពអន្តរាគមន៍អោយមកទទួលជាអនុប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ ។

១០–ផ្ទេរភារកិច្ចលោក ឧត្តមសេនីយ៍ត្រី គន្ធ សំអឿន ពីប្រធាននាយកដ្ឋានប្រឆាំងភេរវកម្មមកទទួលជាប្រធានអង្គភាពអន្តរាគមន៍ ។

១១–ផ្ទេរភារកិច្ចលោក ឧត្តមសេនីយ៍ត្រី ហ៊ុយ ហឿន ពីប្រធាននាយកដ្ឋាននគរបាលរដ្ឋបាល អោយទៅបំពេញភារកិច្ចប្រចាំការនៅសហអគ្គ មេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ។

១២–ផ្ទេរភារកិច្ចលោក ឧត្តមសេនីយ៍ត្រី អ៊ុក គឹមលេខ ពីអនុប្រធាននាយកដ្ឋានកណ្តាល សន្តិសុខ មកជាប្រធាននាយកដ្ឋាននគរបាល រដ្ឋបាល ។

១៣–តែងតាំងលោក ឧត្តមសេនីយ៍ត្រី លន់ ណេត បច្ចុប្បន្នប្រធាននាយកដ្ឋានអង្គរក្ស ជាអនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ ។

១៤–ផ្ទេរភារកិច្ចលោក ឧត្តមសេនីយ៍ត្រី ស៊ឹម សុផល ពីប្រធាននាយកដ្ឋាននគរបាលការពារ អោយមកទទួលជាប្រធាននាយកដ្ឋានអង្គរក្ស ។

១៥–ផ្ទេរភារកិច្ចលោក ឧត្តមសេនីយត្រី **ម៉ៅយ ម៉ាន** ពីប្រធាននាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ អោយមកទទួលជាប្រធាននាយកដ្ឋាននគរបាលការពារ ។

១៦–ផ្ទេរ និងតែងតាំងលោក **ទាវ៉ន់ រដ្ឋា** ពីអនុប្រធាននាយកដ្ឋានបុគ្គលិក អោយមកទទួលជា ប្រធាននាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ ។

១៧–ផ្ទេរភារកិច្ចលោក ឧត្តមសេនីយ៍ត្រី **ហេង ហាក់** ពីនាយករងខុទ្ទកាល័យ មកទទួលជាប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម ។

១៨–ផ្ទេរ និងតែងតាំងលោក ឧត្តមសេនីយ៍ត្រី **លូ រ៉ាមីន** ពីប្រធាននាយកដ្ឋានជនបរទេសមកទទួលជាទីប្រឹក្សាឯកឧត្តម **ស ខេង** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

១៩–តែងតាំងលោក **ឞួក សារឿន** បច្ចុប្បន្នអនុប្រធាន ជាប្រធាននាយកដ្ឋានជនបរទេស ។

២០–តែងតាំងលោក ឧត្តមសេនីយ៍ត្រី **ខៀវ សុគ័ន** បច្ចុប្បន្នទីប្រឹក្សាឯកឧត្តម **ស ខេង** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អោយទទួលបន្ថែមជានាយករងខុទ្ទកាល័យនៃក្រសួងមហាផ្ទៃ ។

២១–តែងតាំងលោក **ខូវ គីមបាក់** ជាជំនួយការឯកឧត្តម **ស ខេង** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី និង ប្រធានស្ថាប័នពាក់ព័ន្ធ និងអស់លោកដែលមានឈ្មោះដូចក្នុងប្រការ ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ១៣៦ អនក្រ តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម **សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- ពិនិត្យសំណូមពរការងារ និង សមត្ថភាពរបស់មន្ត្រីរាជការ

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងលោក **ជួន រតនា** ជានាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ បណ្តាក្រសួងពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែង ក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ១៣៧ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- ពិនិត្យសំណូមពរការងារ និងសមត្ថភាពរបស់មន្ត្រីរាជការ

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងលោក **ឆូ ស្វាយឆវ្យា** បញ្ចូលក្នុងក្រុមជំនួយការសម្តេចនាយករដ្ឋមន្ត្រីទី២ ទទួលបន្ទុកការងារវិនិយោគ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ បណ្តាក្រសួងពាក់ព័ន្ធ និង សាមីខ្លួនដូចមាន ចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ១៣៨ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- ពិនិត្យសំណូមពរការងារ និងសមត្ថភាពរបស់មន្ត្រីរាជការ

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងលោក **ឈន ម៉េងឡេង**បញ្ចូលក្នុងក្រុមជំនួយការសម្តេចនាយករដ្ឋមន្ត្រី ទី ២ ទទួលបន្ទុកការងារពតិមាន ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ បណ្តាក្រសួងពាក់ព័ន្ធ និង សាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ១៣៩ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-ពិនិត្យសំណូមពរការងារ និង សមត្ថភាពរបស់មន្ត្រីរាជការ

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងលោក **ខាំពូន កែវមុណី** ជានាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ បណ្តាក្រសួងពាក់ព័ន្ធ និងសាមីខ្លួនដូចមាន ចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ១៤០ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើចាំបាច់របស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សំរេច

ប្រការ ១ : តែងតាំងលោក **ទេង សាខុន** និងលោក **លី ចាណរ៉ា** ជាអគ្គនាយករងផារាសាស្ត្រឧតុនិយម និង ជលសាស្ត្រ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីនៃក្រសួង រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន គ្រប់ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

២—សេចក្តីសម្រេច

រាជធានីភ្នំពេញ ,ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៩៦

សេចក្តីសំរេច លេខ ៣០ សសរ

ស្តីពីការប្តូរឈ្មោះមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកណ្តាល

ទៅជា មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ហ៊ុន សែន ខេត្តកណ្តាល

* * *

រាជរដ្ឋាភិបាល

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា

–បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើតាមព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

–បានឃើញព្រះរាជក្រឹត្យលេខ នស.រកត១០៩/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរបស់រាជរដ្ឋាភិបាល

–បានឃើញព្រះរាជក្រមរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

–បានឃើញសេចក្តីសំរេចលេខ ១៣៧ សសរ ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៨៤ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការបង្កើតមជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង ៦ សំរាប់បណ្តុះបណ្តាល និងវិក្រឹតការគ្រូកំរិតសិក្សាទី២

–តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

សំរេច

ប្រការ ១ : អនុញ្ញាតអោយប្តូរឈ្មោះ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកណ្តាល ទៅជា មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ **ហ៊ុន សែន** ខេត្តកណ្តាល ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ត្រូវពាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្តកណ្តាល មានភារកិច្ចរៀងៗខ្លួនអនុវត្តសេចក្តី សំរេចនេះ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

៣—សារាចរណែនាំ

ភ្នំពេញ,ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៩៦

សារាចរណែនាំលេខ ០៤ ស.រ.ណ.ន

ស្តីពីការកំណត់គោលការណ៍ការងារធារាសាស្ត្រ

ព្រះរាជាណាចក្រកម្ពុជា ពឹងផ្អែកទាំងស្រុងទៅលើវិស័យកសិកម្មក្នុងការងារនីតិសម្បទា និង កិច្ចអភិវឌ្ឍន៍ប្រទេសជាតិ ព្រោះប្រជាពលរដ្ឋជាង ៨០ % នៃប្រជាពលរដ្ឋទាំង អស់ជាប្រជាកសិករ ។ នៅគ្រប់សម័យកាលកសិកម្មនៅតែត្រូវបានចាត់ទុកជាវិស័យដ៏សំខាន់ នៃប្រទេសជាតិ ។ ជាក់ស្តែងក្នុងបន្ទាត់ នយោបាយនៃរាជរដ្ឋាភិបាលកម្ពុជាបានកំណត់ច្បាស់ថា : កសិកម្មជាវិស័យអាទិភាព ដែលត្រូវគិតគូរយកចិត្តទុកដាក់អោយបានខ្លាំងក្លា ព្រោះជាបញ្ហាសំខាន់នៃស្ថេរភាពសង្គមក្នុងនេះ ការងារចំបងគឺ " បញ្ហា នយោបាយទឹក" ។

ឈរលើទស្សនៈខាងលើនេះ ការងារស្តារ និង កសាងប្រព័ន្ធធារាសាស្ត្របាន និង កំពុងក្លាយជាចលនាមួយយ៉ាងផុសផុលពីសំណាក់រាជរដ្ឋាភិបាល អង្គការសង្គមអង្គការអន្តរជាតិអង្គការក្រៅរដ្ឋាភិបាល ក្រុមហ៊ុនឯកជន និង សប្បុរសជន ។ល។ ប៉ុន្តែទន្ទឹមនឹង

នេះរាជរដ្ឋាភិបាលបានសង្កេតឃើញថា ៖

– សំណង់ធារាសាស្ត្រមួយចំនួនបានអនុវត្តសមស្រប និង ត្រឹមត្រូវទៅតាមលក្ខណៈបច្ចេកទេស រីឯមួយចំនួនទៀតពុំទាន់មានការគិតគូរខ្ពស់ដល់បញ្ហានេះនៅឡើយទេ ។

– មានភាពអនាធិបតេយ្យក្នុងការកសាងលំនៅដ្ឋាននៅលើសំណង់ទ្វារទឹក ខ្នងទំនប ប្រឡាយនាំទឹក ការចាប់ដីធ្លីនៅក្នុងអាងទឹក ការកាប់គាស់ប្រឡាយ–ទំនប់ ការលួចសំភារៈ និង បរិក្ខារសំណង់បញ្ជាទឹក ។ល។ និង ។ល។

ក្នុងគោលបំណងជំរុញដល់ការដាំដុះ ធានាបាននូវសន្តិសុខស្បៀង ទប់ស្កាត់បាននូវភាពអនាធិបតេយ្យ និង ភាពមហន្តរាយនានា ដែលអាចកើតមានឡើងជាយថាហេតុក្រោយពេលសាងសង់សំណង់ធារាសាស្ត្ររួចហើយ និង ក្នុងគោលបំណងថែទាំប្រព័ន្ធស្រោចស្រពអោយស្ថិតក្នុងល័ក្ខខ័ណ្ឌនៃការប្រើប្រាស់យូរអង្វែង ពង្រីកបាននូវសមត្ថភាពនៃការប្រើប្រាស់ និង សក្តានុពលនៃការស្រោចស្រព ព្រមទាំងកាត់បន្ថយបាននូវការចំណាយជាប្រចាំរបស់រាជរដ្ឋាភិបាលលើការងារថែទាំ និង ប្រើប្រាស់ប្រព័ន្ធធារាសាស្ត្ររាជរដ្ឋាភិបាលសូមធ្វើការណែនាំស្តីពីការកំណត់គោលការណ៍លើការងារធារាសាស្ត្រដូចតទៅ ៖

I-អំពីការកំណត់ប្រភេទប្រព័ន្ធធារាសាស្ត្រ :

១–ប្រភេទតូច : គឺប្រព័ន្ធធារាសាស្ត្រ ដែលមានលទ្ធភាពស្រោចស្រពលើផ្ទៃដីក្រោម ២០០ ហិកតា ។

២– ប្រភេទមធ្យម : គឺប្រព័ន្ធធារាសាស្ត្រ ដែលមានលទ្ធភាពស្រោចស្រពលើផ្ទៃដីពី ២០០ ហិកតា ទៅ ៥០០០ ហិកតា ។

៣– ប្រភេទធំ : គឺប្រព័ន្ធធារាសាស្ត្រ ដែលមានលទ្ធភាពស្រោចស្រព លើផ្ទៃដីលើសពី ៥០០០ ហិកតា និង មានផលប្រយោជន៍លើច្រើនវិស័យ ។

II-អំពីគោលការណ៍នៃការអនុវត្តន៍ការងារ :

១– ការងារសិក្សាគ្រោងប្លង់ : ចែកចេញជា ២ ផ្នែក ៖

ផ្នែកទី ១ : ការងារសិក្សាគ្រោងប្លង់ចំពោះមុខនោះគឺប្រភេទតូច ដែលជាការ

ក្រុង និង មិនមានវិទ្ធិរលាយបំពាក់លេខប្រព័ន្ធខ្នាតធំ ជាសមត្ថកិច្ចរបស់ការិយាល័យធារាសាស្ត្រ ឧតុនិយម និង ជលសាស្ត្រ ខេត្ត–ក្រុង តែចាំបាច់ត្រូវអនុវត្តទៅតាមបទដ្ឋានបច្ចេកទេសដោយឆ្លងតាមការត្រួតពិនិត្យពី អគ្គនាយកដ្ឋានធារាសាស្ត្រឧតុនិយម និងជលសាស្ត្រនិងរាយការណ៍ជាប្រចាំអំពីលទ្ធផលសំរេចបាន ។

ផ្នែកទី ២ : ការងារសិក្សាគ្រោងប្លង់ធារាសាស្ត្រ ប្រភេទមធ្យម និង ធំ ដែលទាមទាររយៈពេលយូរ ចំណាយថវិកាច្រើន និង មានការពាក់ព័ន្ធស្មុគស្មាញ ជាសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានធារាសាស្ត្រឧតុនិយម និង ជលសាស្ត្រទាំងស្រុង ។

២– <u>ការងារជួសជុល និង សាងសង់</u> : ការងារនេះចែកជា ៤ ផ្នែក ÷

ផ្នែកទី ១ : ចំពោះសំណង់ធារាសាស្ត្រប្រភេទតូច ដែលម្ចាស់ការដោយប្រជាជនផ្ទាល់ការិយាល័យធារាសាស្ត្រ ឧតុនិយម និង ជលសាស្ត្រខេត្ត–ក្រុង ជាអ្នកណែនាំបច្ចេកទេស ។

ផ្នែកទី ២ : សំណង់ធារាសាស្ត្រប្រភេទមធ្យមដែលរដ្ឋ និង ប្រជាជនរួមគ្នាធ្វើ អគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និង ជលសាស្ត្រជាអ្នកទទួលខុសត្រូវលើការងារសិក្សាគ្រោងប្លង់វិការអនុវត្ត ត្រូវមានការចូលរួមពីសំណាក់ការិយា ល័យធារាសាស្ត្រឧតុនិយម និងជលសាស្ត្រខេត្ត–ក្រុង និងប្រជាជន ។

ផ្នែកទី ៣ : ចំពោះសំណង់ធារាសាស្ត្រប្រភេទមធ្យមប្រើប្រាស់ដោយថវិការដ្ឋ អគ្គនាយកដ្ឋាន ធារាសាស្ត្រឧតុនិយម និង ជលសាស្ត្រជាអ្នកទទួលខុសត្រូវទាំងស្រុង ។

ផ្នែកទី ៤ : ចំពោះសំណង់ធារាសាស្ត្រប្រភេទធំ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទជាអ្នកទទួលខុសត្រូវ និង ពិភាក្សាជាមួយបណ្តាក្រសួងមួយចំនួនទៀត ដែលមានការពាក់ព័ន្ធ ។

III-អំពីការងារគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ :

ការងារនេះចែកចេញជា ៤ ផ្នែក ÷

ផ្នែកទី ១ : ប្រព័ន្ធធារាសាស្ត្រប្រភេទតូច និងមធ្យមដែលស្ថិតក្នុងស្រុក–ខ័ណ្ឌតែមួយជាសមត្ថ កិច្ចរបស់ធារាសាស្ត្រស្រុក–ខ័ណ្ឌសាមី ។ ក្នុងករណីដែលប្រព័ន្ធធារាសាស្ត្រប្រភេទនេះមានការពាក់ព័ន្ធរវាងស្រុក–ខ័ណ្ឌ និង ស្រុក–ខ័ណ្ឌ ជាសមត្ថកិច្ចរបស់ការិយាល័យធារាសាស្ត្រ ឧតុនិយម និង ជលសាស្ត្រ ខេត្ត–ក្រុង ។

ផ្នែកទី ២ : ប្រព័ន្ធធារាសាស្ត្រប្រភេទតូច និង មធ្យមដែលស្ថិតក្នុងខេត្ត–ក្រុងតែមួយជាសមត្ថកិច្ចរបស់ការិយាល័យធារាសាស្ត្រ ឧតុនិយម និង ជលសាស្ត្រខេត្ត–ក្រុង ។ ក្នុងករណីដែលប្រព័ន្ធ ធារាសាស្ត្រប្រភេទនេះមានការពាក់ព័ន្ធរវាងខេត្ត–ក្រុង និង ខេត្ត–ក្រុង ជាសមត្ថកិច្ចរបស់អគ្គនាយកដ្ឋាន ធារាសាស្ត្រឧតុនិយម និង ជលសាស្ត្រ ។

ផ្នែកទី ៣ : ប្រព័ន្ធធារាសាស្ត្រប្រភេទធំ ជាសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និង ជលសាស្ត្រ ។

ផ្នែកទី ៤ : ចំពោះប្រព័ន្ធធារាសាស្ត្រ ដែលរដ្ឋបានប្រគល់ជូនអង្គភាព ក្រុមហ៊ុនឯកជន អង្គការសង្គមនានាគ្រប់គ្រង ការងារជួសជុលថែទាំជាបន្ទុករបស់សាម៉ីខ្លួន ។

IV-អំពីការងារអន្តរាគមន៍ទប់ទល់នឹងគ្រោះទឹកជំនន់ :

នៅពេលមានគ្រោះទឹកជំនន់ ដែលបង្កអោយមានអន្តរាយដល់អាយុជីវិតមនុស្ស–សត្វ ទ្រព្យសម្បត្តិ ផលដំណាំរបស់ប្រជារាស្ត្រ អង្គភាពធារាសាស្ត្រ និង អាជ្ញាធរដែនដីត្រូវចាត់ការអន្តរាគមន៍ទប់ទល់ជាបន្ទាន់ និង រាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ "អគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និងជលសាស្ត្រ" ដើម្បីមានវិធានការជាបន្ទាន់ ។

V-អំពីការងារអន្តរាគមន៍ទប់ទល់នឹងគ្រោះរាំងស្ងួត :

ផ្នែកទី ១ : គ្រោះរាំងស្ងួតដែលកើតមានឡើងនៅក្នុងក្របខ័ណ្ឌ ឃុំ–សង្កាត់ភ្នាក់ងារធារាសាស្ត្រកសិកម្មស្រុក–ខ័ណ្ឌនិង អាជ្ញាធរដែនដីត្រូវចាត់ការអន្តរាគមន៍ទៅតាមលទ្ធភាពជាក់ស្តែង និង រាយការណ៍ ទៅការិយាល័យធារាសាស្ត្រឧតុនិយម និង ជលសាស្ត្រខេត្ត–ក្រុងរៀងខ្លួនជាបន្ទាន់ ។

ផ្នែកទី ២ : គ្រោះរាំងស្ងួតដែលកើតមានឡើងនៅក្នុងក្របខ័ណ្ឌខេត្ត–ក្រុង ការិយាល័យធារាសាស្ត្រ និង អាជ្ញាធរដែនដីត្រូវចាត់ការអន្តរាគមន៍ទៅតាមលទ្ធភាពជាក់ស្តែង និង រាយការណ៍ទៅអគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយមនិងជលសាស្ត្រជាបន្ទាន់ ។

ផ្នែកទី ៣ : គ្រោះរាំងស្ងួតដែលកើតមានឡើងនៅក្នុងក្របខ័ណ្ឌទូទាំងប្រទេសជាសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានធារាសាស្ត្រឧតុនិយមនិងជលសាស្ត្រ ។

VI-ការកំណត់ទីតាំងសំណង់ប្រព័ន្ធធារាសាស្ត្រ :

រាល់ការសាងសង់ប្រព័ន្ធធារាសាស្ត្រ ត្រូវមានការគិតគូរខ្ពស់ដល់ការងារការពារបរិស្ថានប្រព័ន្ធជីវសាស្ត្រចំរុះ និង ដែននេសាទ ។

VII-គោលនយោបាយរបស់រាជរដ្ឋាភិបាល :

១–អំពីព្រេងបូមទឹកប្រឡាយមេ :

រាជរដ្ឋាភិបាលបានអនុវត្តគោលនយោបាយប្រឡាយមេ ដោយប្រគល់ភារកិច្ចអោយអគ្គនាយកដ្ឋានធារាសាស្ត្រឧតុនិយម និង ជលសាស្ត្រ នៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទទទួលបន្ទុកអនុវត្តការងារនេះ ។

២–ការងាររៀបចំសមាគមកសិករប្រើប្រាស់ទឹក :

អគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយមជលសាស្ត្រ នៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ មានភារកិច្ចណែនាំរៀបចំចងក្រងត្រួតពិនិត្យនូវរាល់សមាគមប្រើប្រាស់ទឹក ដើម្បីធានាការគ្រប់គ្រង និង ប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រដោយភាពម្ចាស់ការ និង មានប្រសិទ្ធភាពខ្ពស់ ។

៣–អំពីការងារស្តារ និង កសាងប្រព័ន្ធធារាសាស្ត្រ :

រាជរដ្ឋាភិបាលមានគោលនយោបាយលើកទឹកចិត្តដល់ក្រុមហ៊ុនឯកជន អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ ឬបុគ្គលដែលបានបណ្តាក់ទុនលើការស្តារ និង កសាងប្រព័ន្ធធារាសាស្ត្រ តែត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យពីអគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និង ជលសាស្ត្រនៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ។

៤–អំពីការរៀបចំរបៀបរបបដាំដុះ :

ចំពោះតំបន់ដែលផលិតស្រូវឡើងទឹក គប្បីពិនិត្យលទ្ធភាពបង្វែរទៅធ្វើស្រូវស្រាលជំនួសវិញ ដោយផ្តល់អាទិភាពខ្ពស់លើការស្តារ និង រៀបចំប្រព័ន្ធធារាសាស្ត្រមធ្យម និងតូច នៅតំបន់នេះ និង នៅតំបន់ប្រពលវប្បកម្ម និង បង្កើនរដូវ ដើម្បីជំរុញទិន្នផលខ្ពស់ឡើង ។

រាជរដ្ឋាភិបាលសង្ឃឹមយ៉ាងកក់ក្ដៅបំផុត ចំពោះគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន ខេត្ត ក្រុង អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិនានា នឹងលើកកំពស់ឆន្ទៈ អនុវត្តសារាចរណែនាំនេះអោយបានជោគជ័យ ។

នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

II ការងារបណ្ដាក្រសួង

១—ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១១៩ សហវ. ប្រក. ប

ស្ដីពីការទទួលស្គាល់បុគ្គលិកអតីតរចនាសម្ព័ន្ធ

របស់គាត់ រ.ជ.រ.ម.ខ ចំនួន ១០៨ នាក់ និង

អ្នកបច្ចេកទេសដែលទើបបញ្ចប់ការសិក្សាពីក្នុង

និងក្រៅប្រទេស ចំនួន ៨៥ នាក់ អោយមកបំពេញ

ការងារក្នុងក្របខ័ណ្ឌក្រសួង

* * *

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

– បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

